**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៤២..សសរ.

# សេចក្តីសម្រេច
## ស្តីពី
## ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល កម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋានដើម្បី ត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់ រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល



www.pheakdeylaw.com

## សម្រេច

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្ត កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តមួយចំនួនដូច ខាងក្រោម៖

| | |
|---|---|
| ១.ឯកឧត្តម ប៉ាវ ហមផាន | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ជាសមាជិកក្រុមការងារខេត្តកំពង់ឆ្នាំង |
| ២.ឯកឧត្តម អ៊ុក សិទ្ធិជាតិ | អគ្គនាយក នៃអគ្គនាយកដ្ឋានកីឡា ក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិកក្រុមការងារខេត្តព្រៃវែង |
| ៣.ឯកឧត្តម ប៊ុន ណារិទ្ធ | អគ្គនាយក អាជ្ញាធរអប្សរា ជាសមាជិកក្រុមការងារខេត្តសៀមរាប |
| ៤.ឯកឧត្តម ជា ម៉ន | មេបញ្ជាការយោធភូមិភាគទី៤ក្រសួងការពារជាតិ ជាសមាជិកក្រុមការងារខេត្តសៀមរាប |
| ៥.លោក ព្រុំ ធី | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសមាជិកក្រុមការងារខេត្តព្រៃវែង |
| ៦.លោក យឹម វុទ្ធី | អគ្គនាយករង នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន ជាសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ |
| ៧.លោក ជួន ចាន់ការុណ | អគ្គនាយករង នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន ជាសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ |
| ៨.លោក អ៊ុក កំពូល | ប្រធាននាយកដ្ឋានគ្រប់គ្រងរោងពុម្ព ក្រសួងព័ត៌មាន ជាសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ |
| ៩.លោក ឈុន ប៊ុនលី | អគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងបរិស្ថាន ជាសមាជិកក្រុមការងារខេត្តកណ្ដាល |
| ១០.លោក ឡុង រិទ្ធីរក្ស | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន ជាសមាជិកក្រុមការងារខេត្តតាកែវ |
| ១១.លោក កុច សុវ៉ាទ | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន ជាសមាជិកក្រុមការងារខេត្តបាត់ដំបង |
| ១២.លោក ជួប ប៉ារីស៍ | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រសួងបរិស្ថាន ជាសមាជិកក្រុមការងារខេត្តកំពង់ធំ |
| ១៣.លោក ឈឿង ផល្លាង | អគ្គនាយករងនៃអគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ |



www.pheakdeylaw.com

| | |
|---|---|
| | និងដឹកជញ្ជូន ជាសមាជិកក្រុមការងារខេត្តឧត្តរមានជ័យ |
| ១៤.លោក សែម សុភ័ក្ត្រ | អនុប្រធានផ្នែកបែតង ក្រសួងបរិស្ថាន ជាសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ |

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០.ខែ តុលា ឆ្នាំ២០១៤

**ក.ប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*

*-គ្រប់ក្រសួង ស្ថាប័ន*

*-រដ្ឋបាលថ្នាក់ក្រោមជាតិ*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com